ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ:......318......អ.យ.ធ

# ដីកាសន្និដ្ឋានស្ថាពរ

យើង [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៦២៧៤ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៦៦៣ អ.យ.ណ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ៧៤៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ លិខិតជូនដំណឹងស្តីពីការបិទការស៊ើបសួរលេខ ៨៤៦ "ជ១" ព.ទ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ ៨៦៩ "ជ១" ព.ទ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា:**

១.នាម/គោត្តនាម៖ [redacted] វចនា ភេទប្រុស អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមន្ត្រីនគរបាលជាតិ ទីកន្លែងកំណើត ភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៤នាក់ ទោសពីមុនគ្មាន ជានីតិជន ។

២.នាម/គោត្តនាម៖ [redacted] សារន់ ភេទប្រុស អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង មុខរបរប្រធានការិយាល័យ ទីលំនៅបច្ចុប្បន្នស្នាក់នៅភូ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ទោសពីមុនគ្មាន ជានីតិជន ។

៣.នាម/គោត្តនាម៖ [redacted] សុខុម ភេទប្រុស អាយុ៥៤ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីរាជការ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

៤.នាម/គោត្តនាម៖ [redacted] សុវណ្ណ ភេទប្រុស អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted]

Scanned with CamScanner

ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ជានីតិជន ។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ឆបោក ប្រព្រឹត្តនៅត្រង់ចំណុចភូមិចំការចេក១ ឃុំក្រញូង និង ភូមិព្រៃទូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

**អំពីអង្គហេតុ**[*]៖ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០១៨ ឈ្មោះ [redacted] រចនា ,ឈ្មោះ [redacted]សារន់ ,ឈ្មោះ [redacted]សុខុម និងឈ្មោះ [redacted]សុវណ្ណ បានចុះកិច្ចព្រមព្រៀងទិញលក់ដីជាមួយដើមបណ្តឹង ឈ្មោះ [redacted] ស្រីអ៊ុយ ឈ្មោះ [redacted]តុង [redacted]វ៉ាន់យូ និងឈ្មោះ [redacted]អេង លើផ្ទៃដីសរុបចំនួន ៤១០,៤៦ ហិចតា (បួនរយដប់ក្បៀសសែសិបប្រាំមួយហិចតា) ដែលមានទីតាំងទី១ មានទំហំសរុប ២៣១,៤១ ហិចតា (ពីររយសាមសិបមួយក្បៀសសែសិបមួយហិចតា) មានទីតាំងស្ថិតនៅភូមិចំការចេក១ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង និងទីតាំងទី២ មានទំហំ ១៧៩,០៥ ហិចតា (មួយរយចិតប្រាំបួនក្បៀសសូន្យប្រាំហិចតា) មានទីតាំងស្ថិតនៅភូមិព្រៃទូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង តាមតម្លៃដែលបានឯកភាពដូចនៅក្នុងកិច្ចព្រមព្រៀង ។ ចាប់តាំងពីថ្ងៃចុះកិច្ចព្រមព្រៀងទិញលក់ដីលើកទី១ រហូតមកដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ភាគីអ្នកលក់ទាំងបួននាក់ដែលមានឈ្មោះ [redacted] រចនា [redacted]សុខុម [redacted] សារន់ និងឈ្មោះ [redacted] សុវណ្ណ បានទទួលប្រាក់ជាបន្តបន្ទាប់ពីភាគីអ្នកទិញ ដែលមានឈ្មោះ [redacted] ស្រីអ៊ុយ [redacted]តុង [redacted]ាន់យូ និងឈ្មោះ [redacted]លេង សរុបចំនួន ២,០៣១,៣៨២$ (ពីរលានបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរដុល្លារអាមេរិក) រួចហើយតែភាគីអ្នកលក់ពុំមានដីប្រគល់អោយភាគីអ្នកទិញឡើយ ។

## បានឃើញចំណាត់ការរបស់អយ្យការ

-ដីការចាត់តាំងតំណាងអយ្យការលេខ ៦៣៨២ អ.យ.ក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

- ពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ស្រីអ៊ុយ, [redacted]តុង , [redacted]វ៉ាន់យូ , [redacted]អេង ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ ។
- កំណត់ហេតុសួរចម្លើយរបស់មេធាវីឈ្មោះ [redacted]មនោរម្យ តំណាងឲ្យដើមបណ្តឹងឈ្មោះ [redacted] ស្រីអ៊ុយ, [redacted] តុង, [redacted]វ៉ាន់យូ , [redacted]អេង ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ កាលេពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ កូនក្តីរបស់ខ្លួន បានចុះកិច្ចព្រមព្រៀងទិញលក់ដីជាមួយភាគិអ្នកលក់ដីមានឈ្មោះ [redacted] រចនា,[redacted]សារន់ [redacted]សុខុម និង[redacted]សុវណ្ណ លើផ្ទៃដីទំហំសរុបចំនួន ៤១០,៤៦ ហិចតា (បួនរយដប់ក្បៀសសែសិបប្រាំមួយ) ហិចតា ដែលដីទីតាំងទី១ មានទំហំសុបចំនួន ២៣១,៤១ ហិចតា (ពីររយសាមសិបមួយក្បៀសសែសិបមួយ) ហិចតា មានទីតាំងស្ថិតនៅភូមិចំការចេក១ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង និងដីទីតាំងទី២ មានទំហំ ១៧៩,០៥ (មួយរយចិតសិបប្រាំបួនក្បៀសសិន្យប្រាំ) ហិចតា មានទីតាំងស្ថិតនៅភូមិព្រៃទូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។ គិតចាប់ពីថ្ងៃចុះកិច្ចសន្យាព្រមព្រៀងទិញលក់ដីលើកទី១ រហូតមកដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ភាគីអ្នកលក់ដីទាំងបួននាក់ខាងលើគឺមាន ឈ្មោះ [redacted]រចនា [redacted] សារន់ [redacted]សុខុម និងឈ្មោះ [redacted]សុវណ្ណ បានទទួលប្រាក់ថ្លៃទិញលក់ដីពីកូនក្តី

---

[*] រៀបរាប់សង្ខេបអង្គហេតុ និងកាលចំណាត់ការនៃនីតិវិធីតាមលំដាប់

ខ្លួនជាបន្តបន្ទាប់អស់ចំនួន ២,០៣១,៣៨២$ (ពីរលានបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរដុល្លារអាមេរិក) ប៉ុន្តែពុំមានដីប្រគល់អោយកូនក្តីខ្លួនបានឡើយ ។

- កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ [redacted] សុខុម ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ ក្នុងឆ្នាំ២០១៧ ឈ្មោះ [redacted] រចនា ត្រូវជាក្មួយប្រសាររបស់ខ្លួនបានមកបបួលខ្លួនរៀបចំទិញដីស្ថិតនៅក្នុងឃុំក្របៅ និងឃុំក្រញូង អោយទៅឈ្មោះ [redacted] ស្រីអ៊ុយ និងឈ្មោះ [redacted] វ៉ាន់យូ ក្នុងតម្លៃ ១ហិចតា ៤៥០០$ (បួនពាន់ប្រាំរយដុល្លារអាមេរិក) ហើយឈ្មោះ [redacted] រចនា ប្រាប់ខ្លួនថា គ្រាន់តែអោយខ្លួនឈរឈ្មោះទេ ឯរាល់ការរផបចំទិញដីគឺឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] សុខា ជាអ្នករៀបចំ ។ ក្នុងការរផបចំដីខ្លួនពុំបានចូលរួមទេ ហើយនៅពេលដែលឈ្មោះ [redacted] រចនា រៀបចំទិញដីបានមួយចំនួនអ្នកទាំងបីនាក់បានយកឯកសារជួបជាមួយភាគីអ្នកទិញ ហើយនៅពេលដែលភាគីអ្នកទិញចេញមូលប្បទានប័ត្រមកអោយតាមធនាគារអេស៊ីលីដា គឺមានរូបខ្លួន ឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សារន់ ឈ្មោះ [redacted] សុវណ្ណ ជាអ្នកយកទៅទូរទាត់ទៅអោយប្រជាពលរដ្ឋជាអ្នកលក់ដី ។ ខ្លួនពុំបានដឹងច្បាស់ទេ ថាឈ្មោះ [redacted] រចនា បានទិញដីទៅអោយឈ្មោះ [redacted] ស្រីអ៊ុយ និងឈ្មោះ [redacted] វ៉ាន់យូ ប៉ុន្មានហិចតាទេ ។ ចំណែកប្រាក់ដែលខ្លួនបានទៅយកពីធនាគារអេស៊ីលីដាក៏ពុំដឹងចំនួនប៉ុន្មានដែរ ។

-កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ [redacted] រចនា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ មានខ្លួន ឈ្មោះ [redacted] សុវណ្ណ [redacted] សុខុម និង [redacted] សារន់ ពិតជា បានធ្វើកិច្ចព្រមព្រៀងទិញដីនៅចំណុច៖ ភូមិចំការចេក ១ ឃុំក្រញូង និងភូមិព្រៃទូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ទំហំ ៣១៨ហិចតា មានតម្លៃព្រមព្រៀងជាមួយក្រុមហ៊ុន ១ហិចតា ៤៥០០$ ។ ចំពោះដីដែលខ្លួនប្រមូលទិញពីប្រជាពលរដ្ឋបានចំនួន នៅឃុំក្របៅ បាន៣៨ហិចតា ឃុំក្រញូងបាន៦៨ហិចតា ខ្លួនបានយកលុយពុំបានគ្រប់ចំនួនឲ្យក្រុមហ៊ុន ព្រោះប្រជាពលរដ្ឋចេះតែលក់ដីឡើងថ្លៃរហូត មានដល់កន្លែងខ្លះតម្លៃ ១៥០00 (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ទៅ ១៨០០០ (មួយម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ក្នុងមួយហិចតា និងមានឈ្មួញទិញកាត់មុខដើម្បីលក់តម្លើងថ្លៃ ។ ដីទំហំ៦៨ហិចតា នៅក្នុងភូមិក្រញូងបានផ្ទេសិទ្ធជូនក្រុមហ៊ុនរួចហើយថែមទាំងបានធ្វើប្លង់ជាប្រព័ន្ធដាក់ឈ្មោះ ក្រុមហ៊ុនរួចហើយដែរ ឯដី៣៨ហិចតា នៅក្នុងភូមិក្រញូងបានផ្ទេរសិទ្ធិក្រុមហ៊ុនរួចហើយ ដែលមានឯកសារចុះហត្ថលេខា ត្រឹមភូមិឃុំ ឯដីបួនប្លង់ទៀតនៅជាប់ផ្លូវជាតិផ្លូវលេខ៨អាស្ថិតនៅភូមិ ព្រៃទូលថ្មី (មិនចាំទំហំ) កាលទិញ អស់១៧៣០០០ (ដប់ប្រាំពីរម៉ឺនបីពាន់ដុល្លារអាមេរិក) ដីនេះក៏ខ្លួនបានប្រគល់ជូនក្រុមហ៊ុនរួចហើយដែរ ។ ដីទាំងបីកន្លែងដែលខ្លួនប្រគល់ឲ្យក្រុមហ៊ុននេះមានលក្ខណៈស្បែកខ្លា មិនជាប់គ្នាទេ ។

- កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ [redacted] សារន់ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ នៅក្នុងអំឡុងឆ្នាំ២០១៧ ឈ្មោះ [redacted] រចនា បានមកបបួលខ្លួនរៀបចំទិញដីនៅក្នុងឃុំក្របៅ និងឃុំក្រញូង អោយទៅឈ្មោះ [redacted] ស្រី អ៊ុយ និងឈ្មោះ [redacted] វ៉ាន់យូ ក្នុងតម្លៃ១ហិចតា ៤៥០០ $ (បួនពាន់ប្រាំរយដុល្លារអាមេរិក) ហើយឈ្មោះ [redacted] រចនា ប្រាប់ខ្លួនថា គ្រាន់តែអោយខ្លួនឈរឈ្មោះទេ ឯរាល់ការរៀបចំទិញដីគឺឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] សុខា ។ ក្នុងការរៀបចំដីខ្លួនពុំបានចូលរួមទេ ហើយ



Scanned with CamScanner

នៅពេលដែលឈ្មោះ [redacted] រចនា រៀបចំទិញដីបានមួយចំនួនអ្នកទាំងបីនាក់បានយកឯកសារជួបជាមួយភាគីអ្នកទិញចេញមូលប្បទានប័ត្រមកអោយតាមធនាគារអេស៊ីលីដា គឺមានរូបខ្លួន ,ឈ្មោះ [redacted] រចនា , ឈ្មោះ [redacted] សុវណ្ណ ផ្តិតមេដៃទទួលមូលប្បទានបត្រពីភាគីអ្នកទិញ ហើយមូលប្បទានបត្រនោះទៅបើកប្រាក់នៅធនាគារអេស៊ីលីដា ដោយមានគ្នាទាំងពីរនាក់មានឈ្មោះ [redacted] រចនា , ឈ្មោះ [redacted] សុវណ្ណ រួមទាំងម្ចាស់ដី ដោយពុំមានអនុវត្តអ្នកណាម្នាក់នោះទេ ។ ពេលដែលបានទទួលលុយពីធនាគារហើយខ្លួនពុំបានប៉ះពាល់ ប្រាក់ទាំងនោះទេ ប្រគល់អោយឈ្មោះ [redacted] រចនា និងឈ្មោះ [redacted] សុវណ្ណ ជាអ្នកយកទៅទូទាត់ទៅអោយប្រជាពលរដ្ឋជាអ្នកលក់ដី ។ ខ្លួនពុំបានដឹងច្បាស់ទេ ថាឈ្មោះ [redacted] រចនា បានទិញដីទៅអោយឈ្មោះ [redacted] ស្រីអ៊ុយ និងឈ្មោះ [redacted] វ៉ាន់យូ ប៉ុន្មានហិចតាទេ ។ ចំណែកប្រាក់ដែលខ្លួនទៅយកពីធនាគារអាស៊ីលិដាក៏ពុំដឹងចំនួនប៉ុន្មានដែរ ។ រាល់ការទិញដីភាគីក្រុមហ៊ុនបានពិនិត្យផ្ទៀត ផ្ទាត់ឯកសារបញ្ជាក់ឈ្មោះ អ្នកលក់ អ្នកទិញយ៉ាងច្បាស់លាស់ មុនពេលចេញមូលប្បទានបត្រអោយទៅភាគីអ្នកលក់ដី ហើយបានចេញមូលប្បទានបត្រចំឈ្មោះនីមួយៗអោយទៅម្ចាស់ដីតែម្តង ។ ចំពោះការដោះស្រាយបណ្តឹងខាងលើឈ្មោះ [redacted] រចនា បានសន្យាជាមួយខ្លួនថាអ្នកទទួលខុសទាំងស្រុងតែម្នាក់ឯងជាមួយឈ្មោះ [redacted] ស្រីអ៊ុយ និងឈ្មោះ [redacted] វ៉ាន់យូ ពុំឲ្យខ្លួនបានទទួលខុសត្រូវឡើយ ព្រោះខ្លួនពុំបានពាក់ព័ន្ធឡើយ ។

- កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា ៖ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៧ មានរូបខ្លួន , [redacted] រចនា , [redacted] សុខុម និង [redacted] សារន់ ពិតជាបានធ្វើកិច្ចព្រមព្រៀងទិញដីនៅចំណុច ភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃទូលថ្មី ឃុំក្រចៅ ស្រុកកំចាយមារ ខេត្តព្រៃវែងទំហំ ៣១៨ហិចតា មានតម្លៃព្រមព្រៀងជាមួយក្រុមហ៊ុន ១ហិចតា ៤៥០០$ (បួនពាន់ប្រាំរយដុល្លារអាមេរិក) ។ ចំពោះដីដែលខ្លួនបានប្រមូលទិញពីប្រជាពលរដ្ឋបានចំនួន ឃុំក្រចៅបាន៣៨ ហិចតា ឃុំក្រញូងបាន ៦៨ហិចតា ខ្លួនបានយកលុយពីក្រុមហ៊ុនជាង២,០០០,០០០ (ជាងពីរលានដុល្លារអាមេរិក) ។ មូលហេតុដែលខ្លួនទិញពុំបានគ្រប់ចំនួនព្រោះប្រជាពលរដ្ឋចេះតែលក់ឡើងថ្លៃរហូត មានដល់កន្លែងខ្លះតម្លៃ ១៥០០០ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ទៅ ១៨០០០ (មួយម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ក្នុងមួយហិចតា និងមានឈ្មួញទិញកាត់មុខដើម្បីលក់តម្លើងថ្លៃ ។ ខ្លួននិងក្រុមការងាររៀបដីពុំមានដីកម្មសិទ្ធក្នុងទីតាំងដីទាំងពីរកន្លែងនោះទេ ។ ដីទំហំ៦៨ហិចតា នៅក្នុងភូមិក្រញូងបានផ្ទេរសិទ្ធិជូនទៅក្នុងហ៊ុនរួចហើយ ថែមទាំងបានធ្វើប្លង់ប្រព័ន្ធដាក់ឈ្មោះក្រុមហ៊ុនរួចហើតដែរ ឯដី៣៨ហិចតានៅក្នុងឃុំក្រចៅ ភាគីខ្លួនបានរៀបចំឯកសារផ្ទេរឲ្យក្រុមហ៊ុនរួចហើយដែរ ដែលមានឯកសារចុះហត្ថលេខា ត្រឹមភូមិ ឃុំ ឯដីបួនប្លង់ទៀតនៅជាប់ផ្លូវជាតិផ្លូវលេខ៨អា ស្ថិតនៅភូមិព្រៃទូលថ្មី (មិនចាំទំហំ) កាលទិញអស់ ១៧៣០០០ (ដប់ប្រាំពីរម៉ឺនបីពាន់ដុល្លារអាមេរិក) ដីនេះខ្លួនក៏បានប្រគល់ឲ្យក្រុមហ៊ុនរួចហើយដែរ ។ ដីទាំងអស់ដែលខ្លួនប្រគល់ជូនក្រុមហ៊ុននេះមានលក្ខណៈស្បែកខ្លា មិនជាប់គ្នាទេ ។

- កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ [redacted] ជឿន ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ រយៈពេលកន្លងមកខ្លួនធ្លាប់បានឃើញឈ្មោះ [redacted] រចនា ទៅប្រមូលទិញដីពីប្រជាពលរដ្ឋនៅភូមិចំការកេច១ ភូមិក្រញូង ដែលមាន១២៤គ្រួសារ ប្រជាពលរដ្ឋក្រោម១ហិចតា ឃើញឈ្មោះ [redacted] រចនា ប្រគល់ប្រាក់ខ្លះនៅខ្លះ ចំណែកអ្នកដែលមានដីទំហំចាប់ពី ១ហិចតាឡើងទៅ ឈ្មោះ [redacted] រចនា ពុំទាន់បានប្រគល់ប្រាក់អោយទេ ក្នុងម្នាក់កក់ចំនួន ២០ដុល្លារអាមេរិក ។ ក្រោយមកប្រជាពលរដ្ឋមកសួរខ្លួនអំពីរឿងដែល



Scanned with CamScanner

ឈ្មោះ [redacted] រចនា ទិញដីពីអ្នកទាំងនោះ ខ្លួនបានប្រាប់ទៅសួរឈ្មោះ [redacted] រចនា ហើយឈ្មោះ [redacted] រចនា បានប្រាប់ទៅភាគីអ្នកលក់ដីនោះថា គាត់ពុំមានប្រាក់អោយទេ គាត់សុំប្រគល់ដីឲ្យទៅម្ចាស់ដើមវិញ ។ ក្រោយមកក្រុមហ៊ុនបានមកសួរខ្លួនថា លុយនោះបានប្រគល់ជាង២លានហើយ ខាងក្រុមហ៊ុនសួរហេតុអ្វីមិនប្រគល់លុយនោះអោយអ្នកលក់ ហើយខ្លួនក៏បាននាំក្រុមហ៊ុនទៅសួរប្រជាពលរដ្ឋដែលជាអ្នកលក់ដី គាត់បានឆ្លើយថា ពុំទាន់បានទទួលប្រាក់ពីឈ្មោះ [redacted] រចនា ទេ ។

- កំណត់ហេតុសួរចម្លើយឈ្មោះ [redacted] ភួង ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ រយៈពេលកន្លងមកខ្លួនធ្លាប់ឃើញឈ្មោះ [redacted] រចនា ទៅប្រមូលទិញដីពីប្រជាពលរដ្ឋនៅភូមិព្រៃទូលថ្មី បានមួយចំនួនពុំដឹងទំហំប៉ុន្មានទេ ដោយខ្លួនធ្លាប់ចុះហត្ថលេខាលើលិខិតលក់ ទិញ រាល់តម្លៃប៉ុន្មានអាស្រ័យលើតម្លៃប្រជាពលរដ្ឋខ្លួនពុំបានដឹងទេ ។

- កំណត់ហេតុសួរចម្លើយឈ្មោះ [redacted] សុខុម ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ រយៈពេលកន្លងមកខ្លួនធ្លាប់បានឃើញឈ្មោះ [redacted] រចនា ទៅប្រមូលទិញដីពីប្រជាពលរដ្ឋនៅភូមិចំការចេកទី១ បានមួយចំនួនពុំដឹងទំហំប៉ុន្មានទេ ដោយខ្លួនធ្លាប់ចុះហត្ថលេខាលើលិខិតលក់ ទិញ រាល់តម្លៃប៉ុន្មានអាស្រ័យលើតម្លៃប្រជាពលរដ្ឋខ្លួនពុំបានដឹងទេ ។

- ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៦៦៣ អ.យ.ណ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញចំណាត់ការរបស់ចៅក្រមស៊ើបសួរ

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ២០២ "ដ១" ព្រ.ទ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ លើឈ្មោះ [redacted] រចនា របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ២០៤ "ដ១" ព្រ.ទ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ លើឈ្មោះ [redacted] សុខុម របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ២០៥ "ដ១" ព្រ.ទ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ លើឈ្មោះ [redacted] សុវណ្ណ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ២០៣ "ដ១" ព្រ.ទ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ លើឈ្មោះ [redacted] សារន់ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្ដីពីការស្តាប់ចម្លើយឈ្មោះ [redacted] ភួង ជាសាក្សី ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ នៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ កន្លងមកខ្លួនធ្លាប់បានឃើញឈ្មោះ [redacted] រចនា ទៅប្រមូលទិញដីពីប្រជាពលរដ្ឋនៅភូមិព្រៃទូលថ្មី បានមួយចំនួនតែពុំដឹងទំហំប៉ុន្មានទេ ដោយពុំដឹងតម្លៃគេទិញលក់ដែរ ព្រោះពេលគេយកឯកសារមកសុំហត្ថលេខា គឺពុំបានដាក់តម្លៃទេ ។ ចំពោះផ្ទៃដីបង្ករបង្កើនផល និងផ្ទៃដីចំការសរុបមានចំនួន ១១១ហិចតា ប៉ុណ្ណោះ ។

-កំណត់ហេតុស្ដីពីការស្តាប់ចម្លើយរបស់ឈ្មោះ [redacted] ធឿន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ នៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ កន្លងមកខ្លួនធ្លាប់ឃើញឈ្មោះ [redacted] រចនា ទៅប្រមូលទិញដីពី



Scanned with CamScanner

ប្រជាពលរដ្ឋ នៅភូមិចំការចេក១ ឃុំក្រញូង មាន១២៤គ្រួសារ ដោយទិញក្នុង១ហិចតា តម្លៃ១ម៉ឺនដុល្លារអាមេរិក ។ ក្នុងចំណោមគ្រួសារខាងលើខ្លះបានលុយគ្រប់ ខ្លះទៀតមិនទាន់បាន ខ្លះបានតែលុយកក់ចំនួន ២០$ ជាដើម ។ ក្រោយមកប្រជាពលរដ្ឋបានមករកខ្លួនឲ្យសួរនាំឈ្មោះ [redacted] រចនា តែឈ្មោះ [redacted] រចនា បានប្រាប់ថាគាត់ពុំមានប្រាក់ឲ្យទេ គាត់សុំប្រគល់ដីឲ្យម្ចាស់ដើមវិញ ។ ក្រោយមកខាងក្រុមហ៊ុនបានមកសួរខ្លួនថា លុយបានប្រគល់ជាង ២លានដុល្លារអាមេរិកហើយ មិចមិនប្រគល់ជូនប្រជាពលរដ្ឋពេលនោះខ្លួនបាននាំក្រុមហ៊ុនទៅសួរប្រជាពលរដ្ឋដែលកកដី ពួកគាត់ថាពុំទាន់ទទួលបានប្រាក់ពីឈ្មោះ [redacted] រចនា ទេ ។ ចំពោះផ្ទៃដីបង្កបង្កើតផលនៅក្នុងភូមិចំការចេក១ មានទំហំប្រហែល១៧០ហិចតា ចំណែកដីចំការមានទំហំប្រហែល១០០ហិចតា ។ ហើយតាមដែលខ្លួនបានដឹងលឺថា ក្រុមហ៊ុននឹងចុះទៅទិញដីនៅភូមិខ្លួនចំនួន ១៧០ហិតចតា ដែលមានឈ្មោះ [redacted] រចនា ជាអ្នកដើរទិញ ហើយទិញតែដីចម្ការទេ តែទិញមិនទាន់គ្រប់ទេ ។ក្នុងការទិញលក់នេះខាងមេភូមិ និងឃុំពុំបានដឹងទេ និងសហការជាមួយឈ្មោះ [redacted] រចនា គឺគេចុះវាស់វែងខ្លួនឯងជាមួយនិងម្ចាស់ដីផ្ទាល់តែម្តង ។

- កំណត់ហេតុស្តីពីការស្តាប់ចម្លើយឈ្មោះ [redacted] សុខុម ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ នៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ ខ្លួនធ្លាប់បានឃើញឈ្មោះ [redacted] រចនា ចុះទៅប្រមូលទិញដីពីប្រជាពលរដ្ឋនៅភូមិចំការចេក១ ឃុំក្រញូង និងមានប្រជាពលរដ្ឋទៅសុំហត្ថលេខាពីខ្លួន លើលិខិតទិញលក់នោះដែរ ។ ខ្លួនពុំបានដឹងពីទំហំដីសរុបពិតប្រាកដ ដែលប្រជាពលរដ្ឋលក់ឲ្យទៅក្រុមហ៊ុននោះទេ ព្រោះប្រជាពលរដ្ឋមកម្តង២ ឬ៣នាក់ ដើម្បីសុំហត្ថលេខា។ តាមខ្លួនសាកសួរប្រជាពលរដ្ឋគេប្រាប់ថាលក់ដីក្នុង១ហិចតាតម្លៃ ១ម៉ឺនដុល្លារអាមេរិក ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី២ លេខ៣៧០ "ជ១" ព្រទ លើឈ្មោះ [redacted] រចនា ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើទី២ លេខ ៣៧៣ "ជ១" ព្រទ លើឈ្មោះ [redacted] សារន់ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី២ លេខ ៣៧២ "ជ១" ព្រទ លើឈ្មោះ [redacted] សុខុម ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី២ លេខ ៣៧១ "ជ១" ព្រទ លើឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី៣ លេខ៥៥១ លើឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី៣ លេខ៥៥២ លើឈ្មោះ [redacted] សារន់ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី៣ លេខ៥៥០ លើឈ្មោះ [redacted] រចនា ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី៣ លេខ៥៥៣ លើឈ្មោះ [redacted] សុខុម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។



Scanned with CamScanner

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី៣ លេខ៥៥២ លើឈ្មោះ [redacted] សារន់ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។ 43/6

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី៣ លេខ៥៩៨ "ជ១" ព្រទ លើឈ្មោះ [redacted] រចនា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី៣ លេខ ៥៩៩ "ជ១" ព្រទ លើឈ្មោះ [redacted] សារន់ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួររបស់សាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី៣ លេខ ៦០០ "ជ១" ព្រទ លើឈ្មោះ [redacted] សុខុម ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធនីភ្នំពេញ ។

-ដីកាបង្គាប់ឲ្យចូលខ្លួនលើកទី៣ លេខ៦០១ "ជ១" ព្រទ លើឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូងរបស់ឈ្មោះ [redacted] រចនា ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូងរបស់ឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូងរបស់ឈ្មោះ [redacted] សារន់ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូងរបស់ឈ្មោះ [redacted] សុខុម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្តីពិការពិភាក្សាដេញដោលចំពោះមុខរបស់ឈ្មោះ [redacted] រចនា ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្តីពិការពិភាក្សាដេញដោលចំពោះមុខរបស់ឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្តីពិការពិភាក្សាដេញដោលចំពោះមុខរបស់ឈ្មោះ [redacted] សារន់ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្តីពិការពិភាក្សាដេញដោលចំពោះមុខរបស់ឈ្មោះ [redacted] សុខុម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

- កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ឈ្មោះ [redacted] រចនា ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ នៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ ចំពោះលុយជាង២លានដុល្លារអាមេរិកនេះ គឺក្រុមខ្លួនបានទទួលជាសែកដែលចេញមកឲ្យខ្លួនទៅបើកលុយឲ្យទៅម្ចាស់ដី និងខ្លះទៀតក្រុមហ៊ុនបានចេញឲ្យទៅម្ចាស់ដីផ្ទាល់ ។ ដីដែលត្រូវបានទិញក្នុងកិច្ចសន្យាគឺ ២៣ជាង ទិញបានជាង៤០០ហិចតា ក្នុងតម្លៃ ៤៥០០$ ក្នុង១ហិចតា ប៉ុន្តែពេលទៅទិញផ្ទាល់ជាក់ស្តែងដីខ្លះ ឡើងដល់១០,០០០ដុល្លារអាមេរិក ខ្លះ ១៥០០០ ខ្លះ ១៨០០០ ដុល្លារ



Scanned with CamScanner

អាមេរិក ទៀត ទើបធ្វើឲ្យការទិញពុំគ្រប់ចំនួនតាមការកំណត់ក្នុងកិច្ចសន្យា ហើយពួកខ្លួនទិញបានតែ ៣៨ហិចតា នៅក្នុងឃុំក្រចៅ, ៦៨ហិចតា នៅក្នុងឃុំក្រញូង និងនៅតាមផ្លូវជាតិ៤៨អា ក្នុងភូមិព្រៃទូលថ្មី ឃុំក្រចៅ ជិត២ហិចតាទៀត សរុបប្រហែល ១០៨ហិចតា ។ ក្នុងលុយជាង ២លានដុល្លារអាមេរិក ខ្លួនទិញដីអស់ នៅសល់ប្រហែល៧០០,០០០ (ចិតសិបម៉ឺនដុល្លារអាមេរិក)គឺចំណាយទៅលើការរត់ការកាត់ឈ្មោះ និងថ្លៃចាយវាយផ្សេងអស់ហើយ ។ ចំពោះដី៦៨ហិចតា នៅឃុំក្រញូង ពួកខ្លួន និងក្រុមហ៊ុនពិតជាបានចុះវាស់វែង និងផ្ទេរសិទ្ធិជូនក្រុមហ៊ុនរួចដោយរត់ទៅសុរិយោដីហើយ តែចេញប្លង់បានឬអត់ខ្លួនពុំដឹងទេ , ៣៨ហិចតាទៀត ផ្ទេរបានត្រឹមស្រុក និង២ហិចតាចុងក្រោយផ្ទេរត្រឹមឃុំ ។

- កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ នៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ ក្រុមការងាររបស់ខ្លួនមានរូបខ្លួន ឈ្មោះ [redacted] រចនា , ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សារន់ ពិតជាបានចុះកិច្ចព្រមព្រៀងទិញដីភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃទូលថ្មី ឃុំក្រចៅ ទំហំ៣១៨ហិចតា ដោយក្នុង១ហិចតា តម្លៃ ៤៥០០$ ប្រាកដមែន ។ ចំពោះលុយដែលទទួលបានាសែគចំនួនជាង២លាន ដុល្លារមែន ក្រុមហ៊ុនបានបើកឲ្យពួកខ្លួន និងបើកឲ្យម្ចាស់ដីផ្ទាល់ខ្លះ ។ ដោយសារដីឡើងថ្លៃជាបន្តបន្ទាប់ទើបធ្វើឲ្យពួកខ្លួនទិញដីពុំបានគ្រប់ចំនួន ដោយបានតែ ៣៨ហិចតា នៅឃុំក្រចៅ និងឃុំក្រញូង ៦៨ហិចតា ប៉ុណ្ណោះ ។

-កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទឈ្មោះ [redacted] សារន់ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ នៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ ខ្លួនបានចូលរួមជាក្រុមការងារទិញដីពីប្រជាពលរដ្ឋជាមួយឈ្មោះ ម៉ាន់ រចនា ដោយគ្រាន់តែឈរឈ្មោះ ហើយខ្លួនពុំបានចុះទៅវាស់វែង ឬទៅទិញពីម្ចាស់ដីផ្ទាល់ទេ ខ្លួគ្រាន់តែបានទៅទទួលសែកពីក្រុមហ៊ុនប៉ុណ្ណោះ ។ ចំនួនលុយសរុបដែលក្រុមហ៊ុនទម្លាក់ឲ្យជាសែកសរុបប្រហែល ២លានដុល្លារអាមេរិក ដោយតម្រូវឲ្យទិញដីជាង ៣០០ហិចតា ពេលនោះគឺ១ហិចតា ៤៥០០ដុល្លារអាមេរិក តែការទិញជាក់ស្តែងបានប្រហែ១០ហិចតា ប៉ុណ្ណោះក៏អស់លុយ ។ ខ្លួនពុំបានដឹងថាឈ្មោះ [redacted] រចនា យកលុយទៅធ្វើអ្វីខ្លះនោះទេ ព្រោះគាត់ជាអ្នកគ្រប់គ្រងលុយដែលក្រុមហ៊ុនបើកឲ្យ ។ មូលហេតុដែលទិញដីមិនគ្រប់តាមកិច្ចព្រមព្រៀង ដោយសារដីឡើងថ្លៃជាបន្តបន្ទាប់ ហើយម្ចាស់លុយក៏បានឯកភាពតាមលុយនោះដែរ ។

-កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទឈ្មោះ [redacted] សុខុម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ នៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ ឈ្មោះ [redacted] រចនា បានបបួលខ្លួនឲ្យចូលរួមរៀបចំទិញដីដែលស្ថិតនៅឃុំក្រចៅ និងឃុំក្រញូង ឲ្យទៅក្រុមហ៊ុនមួយក្នុងតម្លៃ ៤៥០០ ក្នុងមួយហិចតា ដោយឲ្យខ្លួនគ្រាន់តែឈរឈ្មោះ ប៉ុណ្ណោះ រាល់ការទិញ និងរៀបចំឯកសារ គឺឈ្មោះ [redacted] រចនា ជាអ្នករៀបចំ ។ ខ្លួនត្រូវបានគេហៅឲ្យចូលរួមនៅពេលដែលទទួលបានសែកពីម្ចាស់លុយ ដោយឲ្យខ្លួនផ្តិតមេដៃដឹងលីដែរ ។ ចំពោះការទិញដីបានប៉ុន្មានហិចតា និងការទទួលលុយជាសែកពីក្រុមហ៊ុនប៉ុន្មាន គឺខ្លួនពុំដឹងឡើយ ។ កន្លងមកឈ្មោះ [redacted] រចនា ធ្លាប់សន្យាជាមួយខ្លួនថាជាអ្នកទទួលខុសត្រូវទាំងស្រុងតែម្នាក់ឯង ដោយពុំឲ្យខ្លួនពាក់ព័ន្ធឡើយ ដូចមានក្នុងលិខិតបញ្ជាក់របស់ឈ្មោះ [redacted] រចនា ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ស្រាប់ ។

-ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ៦៧៣៦ "ជ១" ដ.ព.ស លើឈ្មោះ [redacted] រចនា ចុះថ្ងៃទី២៧ ខែសីហា



Scanned with CamScanner

ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ៦៧៣៥ "ជ១" ដ.ព.ស លើឈ្មោះ [redacted] សារន់ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ៦៧៣៤ "ជ១" ដ.ព.ស លើឈ្មោះ [redacted] សុខុម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ៦៧៣៣ "ជ១" ដ.ព.ស លើឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៥ "ជ១" ដ.ព.ស លើឈ្មោះ [redacted] រចនា ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៤ "ជ១" ដ.ព.ស លើឈ្មោះ [redacted] សារន់ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៣ "ជ១" ដ.ព.ស លើឈ្មោះ [redacted] សុខុម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦២ "ជ១" ដ.ព.ស លើឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-ពាក្យស្នើសុំបំពេញកិច្ចរបស់មេធាវីឈ្មោះ [redacted] ហេង ការពារសិទ្ធឲ្យឈ្មោះ [redacted] រចនា និងឈ្មោះ [redacted] សុខុម ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ។

-ពាក្យស្នើសុំបំភ្លឺរបស់ឈ្មោះ [redacted] វ៉ាន់យូ ជាដើមបណ្ដឹង ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ នៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា ៖ កិច្ចព្រមព្រៀងទិញដី ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ ដែលមានឈ្មោះ [redacted] តុង ជាអ្នកតំណាងទិញដី (ដែលមានឈ្មោះ [redacted] វ៉ាន់យូ និងឈ្មោះ [redacted] ស្រីអ៊ុយ ជាសាក្សី និងមានបោះត្រា ដឹងឮពីលោកមេឃុំ [redacted] សុខុម ជាមួយអ្នកលក់ឈ្មោះ [redacted] រចនា ,ឈ្មោះ [redacted] សុវណ្ណ ,ឈ្មោះ [redacted] សារន់ និងឈ្មោះ [redacted] សុខុម ជាអ្នកលក់ដីទំហំ៣១៨ហិចតា ដែលមានទីតាំងស្ថិតនៅភូមិចំការចេកទី១ ភូមិចំការចេកទី២ ឃុំក្រញូង និងភូមិកុកពង ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ក្នុងតម្លៃ ៤៥០០$ ។ ចំណែកកិច្ចព្រមព្រៀងបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ដែលមានឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] សារន់ និងឈ្មោះ [redacted] សុខុម ជាអ្នកលក់ដី ហើយឈ្មោះ [redacted] តុង ឈ្មោះ [redacted] វ៉ាន់យូ ឈ្មោះ [redacted] ស្រីអ៊ុយ និងឈ្មោះ [redacted] អេង ជាអ្នកទិញដីទំហំសរុប ៤១០,១៩ ហិចតា ដែលមានទីតាំងស្ថិតនៅភូមិចំការចេកទី១ ឃុំក្រញូង និងភូមិកុកពង ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ដោយពុំមានកែប្រែតម្លៃអ្វីឡើយ។ ដោយអ្នកលក់បានថានាអះអាងថា ដៅដែលបានលក់មកឲ្យក្រុមខ្លួនគឺជាដីកម្មសិទ្ធិរបស់ខ្លួនពិតប្រាកដមែន ដោយពុំមានជាប់ពាក់ព័ន្ធជាមួយដីអ្នកដទៃ ឬក៏យកដីរបស់អ្នកដទៃមកលក់ដោយពុំបានទូទាត់ប្រាក់ឲ្យម្ចាស់ដីឡើយ ។ ហេតុដូចនេះខ្លួនឈ្មោះ [redacted] វ៉ាន់យូ ពុំដែលបានព្រមព្រៀងគ្នាជាមួយឈ្មោះ [redacted] រចនា នោះទេ គឺតម្លៃដីត្រូវអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ ដដែលគ្មានកែប្រែតម្លៃអ្វីទាំងអស់ ហើយក៏គ្មានភស្តុ



Scanned with CamScanner

តាំងណាមកបញ្ជាក់អំពីការកែប្រែតម្លៃទិញលក់ដីនោះដែ ។ ខ្លួនឈ្មោះ [redacted] វ៉ាន់យូ ពុំដែលបានទទួលដីដែលថា ឈ្មោះ [redacted] រចនា បានកាត់ដីស្ថិតនៅអន្លង់ជ្រៃ មានតម្លៃទឹកប្រាក់កន្លះលានដុល្លារអាមេរិក ហើយអ្នកផ្សេងមិនដឹងនោះទេ ។ ការលើកឡើងរបស់ឈ្មោះ [redacted] រចនា គឺគ្មានមូលដ្ឋានច្បាស់លាស់នោះទេ ។ ប៉ុន្តែឈ្មោះនេះធ្លាប់បានលក់ដីដទៃផ្សេងទៀតមកឲ្យខ្លួន ៖ ទី១ មានទំហំ ៣១២៨ ម៉ែត្រការ៉េ ស្ថិតនៅភូមិអំពិល ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ តម្លៃ ៣៧,៥៣៦ $ ។ ទី២ មានទំហំ ២៦៤៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ តម្លៃ ១០,០០០$ ។ ទី៣ មានទំហំ ២៥២៦ ម៉ែត្រការ៉េ ស្ថិតនៅភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ តម្លៃ ១២,៦៣០$ ។ ចំពោះដី៣កន្លែង ដូចមានកិច្ចសន្យាលក់ផ្តាច់ និងលិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ នេះខ្លួនបានទូទាត់ប្រាក់រួចរាល់អស់ហើយ មិនជាប់ពាក់ព័ន្ធជាមួយនិងការទិញដីរួមគ្នាជាមួយក្រុមហ៊ុននោះឡើង ។ ពុំមានការចុះរៀបចំទិញដី ការកក់ដីដាច់ប្រាក់ដូចការលើកឡើងនៅក្នុងពាក្យសុំឲ្យបំពេញកិច្ចនោះទេ ហើយពុំមានភស្តុតាង និងសាក្សីណាមួយបញ្ជាក់ផងនោះ ។ ពុំមានកិច្ចសន្យាណាមួយបញ្ជាក់មកថាខ្លួន ក៏ដូចជាអ្នកទិញដីគ្មានអ្នកណាម្នាក់អាចស្គាល់ប្រជាពលរដ្ឋនោះទេ ពីព្រោះថាខ្លួន និងក្រុមការងារអ្នកទិញដីបានធ្វើកិច្ចសន្យាទិញដីពីជនជាប់ចោទទាំងបួននាក់ខាងលើនេះដោយផ្ទាល់ ដោយពួកគេបានអះអាងថាខ្លួនជាម្ចាស់កម្មសិទ្ធិលើដីដែលយកមកលក់ឲ្យក្រុមខ្លួនតាមតម្លៃ និងទំហំដូចមាននៅក្នុងកិច្ចព្រមព្រៀងទាំងពីរលើក ដោយគ្មានអ្នកដទៃផ្សេងទៀតឡើយ ពីព្រោះថាជនជាប់ចោទទាំងបួនអ្នកគឺជាអ្នកលក់ដី និងជាអ្នកទទួលប្រាក់ដោយផ្ទាល់ពីក្រុមខ្លួន សរុបអស់ចំនួន ២,០៣១,៣៨២$ ។ ប៉ុន្តែតាមការពិតជាក់ស្តែងពីពុំមានដីលក់មកឲ្យក្រុមខ្លួនោះទេ ។ ពុំមានដីពិតប្រាកដ ដើម្បីធ្វើការចុះបញ្ជីមកឲ្យក្រុមខ្លួនអ្នកទិញនោះទេ ពីព្រោះថាការបិទប្រកាសផ្សាយដីដែលជនជាប់ចោទលើកឡើងគឺមានទំហំប្រហែល២០ហិចតា ប៉ុន្តែពុំមានដីពិតប្រាកដនោះទេ នៅពេលធ្វើនីតិវិធីបិទផ្សាយគឺមានប្រជាពលរដ្ឋចុះមកតវ៉ា ដោយពួកគាត់បានលើកឡើងថាជនជាប់ចោទបានកក់ថ្លៃដីតែ ២០$ រួចបាត់មុខរហូត ។ ប្រជាពលរដ្ឋជាអ្នកលក់ដីឈ្មោះ [redacted] សុខ បានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ នៅស្នងការខេត្តព្រៃវែង បានលើកឡើងថាមានប្រជាពលរដ្ឋជាច្រើនមិនទាន់បានទទួលប្រាក់ថ្លៃដីនោះទេ ។ ហេតុនេះការបិទផ្សាយមិនអាចប្រព្រឹត្តទៅបានទេ ដោយសារតែជនជាប់ចោទយកប្រាក់ពីក្រុមខ្លួនអស់ជាច្រើនដោយពុំមានដីពិតប្រាកដដូចការអះអាងក្នុងកិច្ចព្រមព្រៀងលក់ដីនោះទេ ។ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] រចនា ឈ្មោះ [redacted] សុវណ្ណ ឈ្មោះ [redacted] សារន់ និងឈ្មោះ [redacted] សុខុម ត្រូវបានអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចោទប្រកាន់ពីបទឆបោក ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] សារន់ បែរជាមកធ្វើរបាយការណ៍លេខ ៣០/២០ មកប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តអំពីទំនាស់ដីធ្លីដែលខ្លួនឯងផ្ទាល់គឺជាជនត្រូវចោទប្រកាន់ផហដៃរនោះ ហើយថែមទាំងជាអ្នកគូសផែនទីទីតាំងដី ចុះហត្ថលេខាលើគំនូសទីតាំងដីក្នុងពេលដែលខ្លួនកំពុងរងការចោទប្រកាន់ពីបទ ឆបោក ក្នុងរឿងក្តីទាក់ទងនឹងខ្លួនឯងជាអ្នកលក់ដីហើយគ្មានដី ហើយធ្វើគំនូសបង្ហាញទីតាំងដី ដែលគ្មានដីពិតប្រាកដផងនោះ ។ ចំពោះការសុំផ្អាកនីតិវិធីតម្កល់ប្រាក់ ហើយសុំឲ្យជនជាប់ចោទឈ្មោះ [redacted] រចនា ជាអ្នកទទួលការតម្កល់ប្រាក់តែម្នាក់ឯងគឺមិនត្រឹមត្រូវនោះទេ ពីព្រោះថាជនជាប់ចោទទាំងបួននាក់ជាអ្នកស្នើសុំតម្កល់ប្រាក់ដើម្បីកុំអោយមានការឃុំខ្លួន ប៉ុន្តែក្រោយរយៈពេល៤៥ថ្ងៃ គិតចាប់ពី

ថ្ងៃចេញដីកាសម្រេចចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ រហូតមកដល់សព្វថ្ងៃនេះគឺបានហួសរយៈពេលកំណត់ ហើយជនជាប់ចោទមិនត្រូវបានតុលាការចេញដីការបង្គាប់ឲ្យចាប់ខ្លួននោះទេ ។ ចំពោះការសុំឲ្យដើមបណ្តឹងតម្កល់ប្លង់ លិខិតលក់ផ្តាច់នោះ តាមពិតគឺពុំមានឯកសារប្លង់ដី លិខិតលក់ផ្តាច់ណាមួយដែលជនជាប់ចោទបានប្រគល់មកឲ្យខ្លួននោះទេ ចាប់តាំងពីជនជាប់ចោទបានទទួលប្រាក់ពីក្រុមហ៊ុនរបស់ខ្លួន និងក្រុមការងាររួចមកដល់សព្វថ្ងៃគឺគ្មានដី ប្រាក់ក៏បាត់អស់ហើយ ធ្វើឲ្យខ្លួននិងក្រុមការងាទាំងបួននាក់បាត់បង់ផលប្រយោជន៍ ដោយសារតែសកម្មភាពឆបោកប្រាក់ពីជនជាប់ចោទទាំងបួនខាងលើ ។

-ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងសំណុំរឿង ។

## យល់ឃើញថា[2]

- កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០១៨ ឈ្មោះ [redacted] រចនា,ឈ្មោះ [redacted] សារន់ ,ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ បានចុះកិច្ចព្រមព្រៀងទិញលក់ដីជាមួយដើមបណ្តឹង ឈ្មោះ [redacted] ស្រីអ៊ុយ ឈ្មោះ [redacted] តុង [redacted] វ៉ាន់យូ និងឈ្មោះ [redacted] អេង លើផ្ទៃដីសរុបចំនួន ៤១០,៤៦ ហិចតា (បួនរយដប់ក្បៀសសែសិបប្រាំមួយហិចតា) ដែលមានទីតាំងទី១ មានទំហំសរុប ២៣១,៤១ ហិចតា (ពីររយសាមសិបមួយក្បៀសសែសិបមួយហិចតា) មានទីតាំងស្ថិតនៅភូមិចំការចេក១ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង និងទីតាំងទី២ មានទំហំ ១៧៩,០៥ ហិចតា (មួយរយចិតសិបប្រាំបួនក្បៀសសូន្យប្រាំហិចតា) មានទីតាំងស្ថិតនៅភូមិព្រៃទួលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង តាមតម្លៃដែលបានឯកភាពដូចនៅក្នុងកិច្ចព្រមព្រៀង ។ ចាប់តាំងពីថ្ងៃចុះកិច្ចព្រមព្រៀងទិញលក់ដីលើកទី១ រហូតមកដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ភាគីអ្នកលក់ទាំងបួននាក់ដែលមានឈ្មោះ [redacted] រចនា [redacted] សុខុម [redacted] សារន់ និងឈ្មោះ [redacted] សុវណ្ណ បានទទួលប្រាក់ជាបន្តបន្ទាប់ពីភាគីអ្នកទិញ ដែលមានឈ្មោះ [redacted] ស្រីអ៊ុយ, [redacted] តុង, [redacted] វ៉ាន់យូ និងឈ្មោះ [redacted] លេង សរុបចំនួន ២,០៣១,៣៨២$ (ពីរលានបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរដុល្លារអាមេរិក) រួចហើយតែភាគីអ្នកលក់ពុំមានដីប្រគល់អោយភាគីអ្នកទិញឡើយ ។

- តាមចម្លើយបំភ្លឺរបស់មេភូមិឈ្មោះ [redacted] ភួង, [redacted] ជឿន, [redacted] សុខុម បានបញ្ជាក់ថាឈ្មោះ [redacted] រចនា និងឈ្មោះ [redacted] សុវណ្ណ ពិតជាបានដើរទិញដីពីប្រជាពលរដ្ឋនៅ ភូមិព្រៃទួលថ្មី, ភូមិចំការចេក១ , ភូមិក្រញូង និងចុះវាស់វែងជាមួយប្រជាពលរដ្ឋផ្ទាល់ ដោយខាងភូមិឃុំពុំបានដឹងឡើយ ។

- ផ្អែកតាមចម្លើយសារភាពរបស់ឈ្មោះ [redacted] សារន់ និងឈ្មោះ [redacted] សុខុម ឆ្លើយនៅអយ្យការ និងនៅចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹងថា៖ ខ្លួនគ្រាន់តែឈរឈ្មោះតំណាងតែប៉ុណ្ណោះ ដោយមិនបានចុះវាស់វែងដី និងរៀបចំឯកសារទិញដីជាមួយប្រជាពលរដ្ឋនោះទេ ។ តែផ្អែកតាមឯកសារភស្តុតាងដែលមាន កិច្ចព្រមព្រៀងទិញលក់ដី ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងកិច្ចព្រមព្រៀងបន្ថែមចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ លិខិតទទួលប្រាក់ចំនួន១១សន្លឹក គឺសុទ្ធតែមានស្នាមមេដៃ ភាគីទាំង៤នាក់ ឈ្មោះ [redacted] រចនា [redacted] សារន់ [redacted] សុខុម និង [redacted] សុវណ្ណ គឺបានដឹងឮទាំងអស់គ្នា ពុំអាចបាត់ភាគីម្នាក់ណាបានទេ គឺភាគីទាំង៤នាក់ ជាអ្នកទទួលខុសត្រូវ ។ ចំណែកមូលប្បទានប័ត្រជាច្រើនសន្លឹក គឺភាគីទាំងបួននាក់បានទៅបើកពីធនាគារទាំងអស់គ្នា ។

[2]សំអាងហេតុ សំរេចច្បាប



Scanned with CamScanner

- មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] រចនា ភេទប្រុស អាយុ៣៩ឆ្នាំ, [redacted] សារន់ ភេទប្រុស អាយុ៥១ឆ្នាំ, [redacted] សុខុម ភេទប្រុស អាយុ៥៤ឆ្នាំ,និងឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ២៩ឆ្នាំ ពីបទ៖ ឆបោក ប្រព្រឹត្តនៅត្រង់ចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃទូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

ហេតុដូច្នេះសម្រេច

១. ចោទប្រកាន់៖ [redacted] រចនា ភេទប្រុស អាយុ៣៩ឆ្នាំ, [redacted] សារន់ ភេទប្រុស អាយុ៥១ឆ្នាំ, [redacted] សុខុម ភេទប្រុស អាយុ៥៤ឆ្នាំ,និងឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ២៩ឆ្នាំ (ក្រៅឃុំ) ដែលមានសាវតាជាតិខាងលើ ពីបទ៖ ឆបោក ប្រព្រឹត្តនៅត្រង់ចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃទូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២. ស្នើសុំចៅក្រមស៊ើបសួរ៖ បញ្ជូនជនត្រូវចោទឈ្មោះ [redacted] រចនា ភេទប្រុស អាយុ៣៩ឆ្នាំ, [redacted] សារន់ ភេទប្រុស អាយុ៥១ឆ្នាំ, [redacted] សុខុម ភេទប្រុស អាយុ៥៤ឆ្នាំ,និងឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ២៩ឆ្នាំ (ក្រៅឃុំ) <u>ទៅជំនុំជម្រះតាមច្បាប់</u>។

ថ្ងៃព្រហស្បត្តិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

ព្រះរាជអាជ្ញា

[redacted]



Scanned with CamScanner